សំរាប់ការផ្សាយបន្ទាន់ថ្ងៃសុក្រ ទី២៥ ខែមេសា ឆ្នាំ២០០៨

# កម្ពុជាប្រារព្ធទិវាពិភពលោកដើម្បីសុខភាព និង សុវត្ថិភាពការងារ ដោយបង្ហាញពីយុទ្ធនាការ

ប្រទេសកម្ពុជានឹងប្រារព្ធទិវាពិភពលោកដើម្បីសុខភាព និង សុវត្ថិភាពការងារ នៅថ្ងៃច័ន្ទ ទី ២៨ ខែ មេសា ឆ្នាំ ២០០៨ ក្នុងពិធីមួយដែលផ្តោតលើប្រធានបទ « រួមគ្នាកាត់បន្ថយគ្រោះថ្នាក់នៅកន្លែងការងារ »។

ការជ្រើសរើសប្រធានបទរបស់ប្រទេសកម្ពុជា ស្របទៅតាមប្រធានបទជាសកលសំរាប់ការប្រារព្ធទិវាពិភពលោកឆ្នាំ ២០០៨ គឺ «ជីវិតរបស់ខ្ញុំ ការងាររបស់ខ្ញុំ ការងារប្រកបដោយសុវត្ថិភាពរបស់ខ្ញុំ - ការគ្រប់គ្រងហានិភ័យនៅក្នុងបរិយាកាសការងារ » ដែលប្រធានបទនេះត្រូវបានជ្រើសរើសឡើងដោយអ្នករៀបចំកម្មវិធីរបស់អង្គការពលកម្មអន្តរជាតិ (ILO) ។

ក្នុងការប្រារព្ធទិវានេះ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំអោយមានជាយុទ្ធនាការដាក់ទង់សុវត្ថិភាព នៅកន្លែងប្រារព្ធពិធី នៅឯនាយកដ្ឋានពេទ្យការងារ ។ ទង់សុវត្ថិភាព ដែលបានបោះពុម្ពឡើងជាពិសេសនេះ នឹងត្រូវបានចងលំអនៅតាមម៉ូតូទុក ទុក និង ស៊ីក្លូ ដែលនឹងបង្កើតជាក្បួនដំណើរ ។ បដាមួយចំនួននឹងត្រូវបានចងនៅតាមមហាវិថីសំខាន់ៗ នៅរាជធានីភ្នំពេញ ដើម្បីបង្កើនការយល់ដឹងដល់សាធារណជន អំពីសារៈសំខាន់នៃសុខភាព និង សុវត្ថិភាពកាងារ ។

ពិធីនេះនឹងត្រូវប្រារព្ធធ្វើឡើងក្រោមអធិបតីភាព លោកជំទាវ **ប្រាក់ ចន្ធា** រដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនឹងថ្លែងសុន្ទរកថា ក្នុងនាម ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។ លោក **ចន រីតឆតត៍** (John Ritchotte) ប្រធានទីប្រឹក្សាបច្ចេកទេស គំរោងដោះស្រាយវិវាទការងារ តំណាងអង្គការពលកម្មអន្តរជាតិ នឹងថ្លែងសុន្ទរកថាផងដែរនៅក្នុងការបើកពិធីនេះ ។

ពិធីនេះបានការឧបត្ថម្ភគាំទ្រពីអង្គការពលកម្មអន្តរជាតិ តាមរយៈកម្មវិធីជំនួយពហុបច្ចេកទេសរបស់ប្រទេសជប៉ុន និង គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ដែលគំរោងនេះបានជួយបោះពុម្ពសំភារៈផ្សព្វផ្សាយ។

ឯកឧត្តម វេជ្ជបណ្ឌិត **ហ៊ុយ ហានសុង** អនុរដ្ឋលេខាធិការ ទទួលបន្ទុកអនាម័យ និង សន្តិសុខកាងារ សន្តិសុខសង្គម និង ពលកម្មកុមារ នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា «បញ្ហាសុខភាព និង សុវត្ថិភាពកាងារ គួរត្រូវបានចាត់ទុកជាអាទិភាពមួយសំរាប់កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ សេដ្ឋកិច្ចរបស់យើងកំពុងរីកចំរើន ហើយការងារ និង មុខរបរក៏កើនឡើង ដូច្នេះហើយ ពេលនេះគឺជាពេលវេលាសមរម្យ ដើម្បីធានាថាទាំងការងារដែលមានស្រាប់ និង ការងារទើបបង្កើតថ្មី ត្រូវគិតគូរពីការការពារពលកម្ម និង កម្មករនិយោជិតពីគ្រោះថ្នាក់ និង ជំងឺផ្សេងៗ ឱ្យបានត្រឹមត្រូវ ។ កន្លែងការងារប្រកបដោយសុខភាព និង សុវត្ថិភាព នាំឱ្យកើនផលិតភាព និង កាត់បន្ថយភាពក្រីក្រ ដោយការកើនឡើងនូវប្រាក់ចំណូល ។ ក៏ប៉ុន្តែបញ្ហានេះចាំបាច់ត្រូវទាមទារកិច្ចសហការទាំងអស់គ្នា ដើម្បីអនុវត្តវិធានការឱ្យមានប្រសិទ្ធិភាព » ។



ILO Regional Office for Asia and the Pacific
United Nations Building, 11th Floor,
Rajdamnern Nok Avenue,
Bangkok 10200, Thailand

Tel. +66 2 288 1234
Fax. +66 2 288 3062
E-mail: bangkok@ilo.org
www.ilo.org/asia

សំរាប់ជាព័ត៌មាន For information only. Not an official record

លោក **ចន រីតឆតត៍** (John Ritchotte) បានមានប្រសាសន៍ថា “លើកនេះគឺជាឆ្នាំទី ៣ ហើយដែលប្រទេសកម្ពុជា បានប្រារព្ធទិវាពិភពលោកនេះឡើង ដែលសបញ្ជាក់ឱ្យឃើញពីការបន្តប្តេជ្ញា ដើម្បីសុខភាព និង សុវត្ថិភាពការងារ ហើយប្រធានបទសំរាប់ការប្រារព្ធទិវារបស់ប្រទេសកម្ពុជា និង អង្គការពលកម្មអន្តរជាតិ គូសបញ្ជាក់ពីសារៈសំខាន់ នៃការទទួលខុសត្រូវរបស់បុគ្គល ចំពោះសុខភាព និង សុវត្ថិភាពការងារ ។ ទាំងនេះគឺបញ្ជាក់ឱ្យឃើញច្បាស់អំពីព្រឹត្តិការណ៍ដ៏សំខាន់ ដែលថាសុវត្ថិភាពគឺជាបញ្ហារបស់មនុស្សគ្រប់រូប ហើយវាក៏ជាធាតុសំខាន់យ៉ាងក្រៃលែងនៃការងារសមរម្យ ។ ពិធីនៅថ្ងៃទី ២៨ ខែ មេសា នេះ គឺពិតជានឹងជួយបញ្ជូនសារទាំងនេះដល់សាធារណជន អំពីគោលបំណងនៃការងារសមរម្យសំរាប់ទាំងអស់គ្នា ”។

អ្នកចូលរួមប្រមាណជា ៣០០ នាក់ មកពីក្រសួងនានារបស់រដ្ឋាភិបាល ដូចជាក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងនគររូបនីយកម្ម ដែនដី និង សំណង់ ក្រសួងសុខាភិបាល និង ក្រសួងសាធារណការ និង ដឹកជញ្ជូន នឹងចូលរួមនៅក្នុងពិធីនេះ ហើយក៏មានការអញ្ជើញចូលរួមពីសំណាក់កម្មករនិយោជិត និយោជក អង្គការមិនមែនរដ្ឋាភិបាល និង ពីអ្នកធ្វើការទាំងផ្នែកក្នុងប្រព័ន្ធ និង ផ្នែកក្រៅប្រព័ន្ធផងដែរ ។

គេបានប៉ាន់ប្រមាណថាមានមនុស្សជាង ១៥០០ នាក់ បានស្លាប់ ជារៀងរាល់ឆ្នាំ ដោយសារគ្រោះថ្នាក់ការងារ ដែលមានចំនួនស្មើនឹងបួននាក់ក្នុងមួយថ្ងៃ [១]។ មានគ្រោះថ្នាក់ធ្ងន់ធ្ងរចំនួនប្រហែល ១,៦ លានករណី កើតមាននៅតាមកន្លែងការងារជារៀងរាល់ឆ្នាំ ។ នៅក្នុងឧស្សាហកម្មមួយ គឺវិស័យកាត់ដេរ ដែលជាវិស័យសេដ្ឋកិច្ចយ៉ាងសំខាន់ មានកម្មករនិយោជិតប្រហែល ៣៦៥ នាក់ នៅតាមរោងចក្រកាត់ដេរក្នុងរាជធានីភ្នំពេញបានទទួលរងគ្រោះថ្នាក់ការងារក្នុងឆ្នាំ ២០០៦ [២] ។

សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:

លោកទន្តបណ្ឌិត ឡេង តុង
ប្រធាននាយកដ្ឋានពេទ្យការងារ
ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
ទូរស័ព្ទលេខ: ០២៣ ២២៤ ០៧៤
អ៊ីម៉ែល: lengtong@online.com.kh

លោក ទុន សុភ័ណ
ទីប្រឹក្សា
*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*
របស់អង្គការពលកម្មអន្តរជាតិ
ទូរស័ព្ទលេខ: ០២៣ ២១២ ៨៤៧
អ៊ីម៉ែល: tun@ilo.org

---

[1] របាយការណ៍ឆ្នាំ ២០០៥ របស់ធនាគារពិភពលោក ដែលប្រើទិន្នន័យប្រមូលបានក្នុងឆ្នាំ ២០០១

[2] យោងតាមតួលេខរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ